សូមបិទប្រកាសនៅកន្លែងដែលបុគ្គលិកអាចអានបានយ៉ាងងាយស្រួល
អ្នករំលោភបំពានត្រូវប្រឈមនឹងការពិន័យ

# សេចក្តីជូនដំណឹងជាផ្លូវការ

**ជូនចំពោះនិយោជក និងនិយោជិកដែលកំពុងធ្វើការនៅក្នុងមុខងារក្នុងទីក្រុង Berkeley**

# ប្រាក់ឈ្នួលអប្បបរមា នៅ Berkeley

| $16.32 | $16.99 | $16.99 + CPI |
|---|---|---|
| ក្នុងមួយម៉ោងមានប្រសិទ្ធភាពនៅថ្ងៃទី ១ ខែកក្កដាឆ្នាំ ២០២១ | ក្នុងមួយម៉ោងមានប្រសិទ្ធភាពថ្ងៃទី ១ ខែកក្កដាឆ្នាំ ២០២២ | ក្នុងមួយម៉ោងមានប្រសិទ្ធភាពថ្ងៃទី ១ ខែកក្កដាឆ្នាំ ២០២៣ |

**កំណើននាពេលអនាគត៖** ចាប់ផ្តើមនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2019 ហើយបន្ទាប់មកនៅថ្ងៃទី 1 ខែកក្កដារៀងរាល់ឆ្នាំ ប្រាក់ឈ្នួលអប្បបរមានេះនឹងកើនឡើងក្នុងកំណើននៃឆ្នាំប្រតិទិនមុន បើសិនជាមាន នៅក្នុងសន្ទស្សន៍ថ្លៃទំនិញអ្នកប្រើប្រាស់ (CPI) សម្រាប់អ្នករកប្រាក់ឈ្នួលទីក្រុង និងបុគ្គលិកជាស្មៀនសម្រាប់តំបន់ស្ថិតិទីក្រុង San Francisco-Oakland-San Jose, CA។

ប្រាក់ទឹកតែ និង/ឬ ប្រាក់ឧបត្ថម្ភ មិនអាចត្រូវបានប្រើដើម្បីសម្រេចបាននូវអត្រាប្រាក់ឈ្នួលអប្បបរមាទេ។ បទប្បញ្ញត្តិបន្ថែមទៀតដែលទាក់ទងទៅនឹងការប្រមូលនិងការចែកចាយនៃ "ថ្លៃសេវា" សម្រាប់អាជីវកម្មសេវាកម្មម្ហូបអាហារ និងបដិសណ្ឋារកិច្ច មានប្រសិទ្ធិភាពនៅថ្ងៃទី 1 ខែតុលាឆ្នាំ 2016។

**ការបង់ថ្លៃពេលឈប់សម្រាកដោយឈឺ - BMC (Berkeley Municipal Code)ផ្នែកទី 13.100** -
បុគ្គលិកមួយរូបៗគួរទទួលបានមួយការបង់ថ្លៃសម្រាប់ការឈប់សម្រាកដោយឈឺមួយម៉ោង សម្រាប់រាល់សាមសិប (30) ម៉ោងធ្វើការ ហើយអាចប្រើការឈប់សម្រាកដោយឈឺនេះបន្ទាប់ពី 90 ថ្ងៃប្រតិទិន។ និយោជកផ្តល់ប្រាក់សម្រាកពេលឈឺដែលបានបូក នៅក្នុងកំណត់ត្រាបញ្ជីបើកប្រាក់ខែ។

**Berkeley Family Friendly and Environment Friendly Workplace Ordinance BMC - ផ្នែកទី 13.101**-
បុគ្គលិកនីមួយៗមានសិទ្ធិដើម្បីស្នើសុំកាលវិភាគការងារមួយដែលអាចបត់បែន ឬព្យាករបាន។ និយោជកត្រូវតែឆ្លើយជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 21 ថ្ងៃតបទៅនឹងសំណើជាលាយលក្ខណ៍អក្សរ។

សិទ្ធិរបស់និយោជិកនៅក្រោមបញ្ញត្តិការងាររបស់ទីក្រុង ត្រូវបានការពារពីការសងសឹក។ និយោជិកម្នាក់ ឬបុគ្គលផ្សេងទៀតណាមួយអាចរាយការណ៍ទៅទីក្រុង ពីការរំលោភសង្ស័យណាមួយ នៃបញ្ញត្តិស្តង់ដាការងារ។ ទីក្រុងនេះនឹងស៊ើបអង្កេតការរំលោភដែលអាចមាន ចូលដំណើរការកំណត់ត្រាបញ្ជីបើកប្រាក់ខែ និងការពង្រឹងវិធានការកែប្រែការរំលោភបំពាននៃតម្រូវការស្តង់ដារការងារ។

**ប្រសិនបើអ្នកមានសំណួរ សូមទាក់ទងនិយោជករបស់អ្នក ឬទីក្រុង Berkeley៖**
**នាយកដ្ឋានសុខភាព លំនៅដ្ឋាន និងសេវាសហគមន៍**
**(510) 981-CITY/2489 ឬ 311 ពីខ្សែដីណាមួយនៅក្នុង Berkeley**
**www.cityofberkeley.info/Labor**
**អ៊ីម៉ែល៖ Rules4work@cityofberkeley.info**
*មានការបកប្រែភាសា*

2180 Milvia Street, Berkeley, CA 94704
●ទូរស័ព្ទលេខ៖(510) 981-2489 ឬ 311 ពីខ្សែទូរស័ព្ទណាមួយ ●TDD៖ (510) 981-6903 ●ទូរសារ៖ (510) 981-5460
អ៊ីម៉ែល៖ MWO@cityofberkeley.info វេបសាយ៖ http://www.CityofBerkeley.info/MWO